**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តស្វាយរៀង**

**គណៈកម្មាធិការលទ្ធកម្មរដ្ឋបាលខេត្ត**

លេខ៖០០៥.២/១៨ ស.ជ.ណា

**សេចក្តីជូនដំណឹង** លទ្ធកម្មរដ្ឋបាលខេត្តស្វាយរៀង

**ស្តីពី**

**ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់**

**ប្រេងឥន្ធនៈសម្រាប់ឆមាសទី២ ឆ្នាំ២០១៨ ជូនសាលាខេត្តស្វាយរៀង**

រដ្ឋបាលខេត្តស្វាយរៀង សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា៖ រដ្ឋបាលខេត្តស្វាយរៀង នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈដើម្បីផ្គត់ផ្គង់ប្រេងឥន្ធនៈ សម្រាប់ឆមាសទី២ ឆ្នាំ២០១៨ ជូនសាលាខេត្តស្វាយរៀង។

រដ្ឋបាលខេត្តស្វាយរៀង បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុនបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្ត អាសយដ្ឋានសាលាខេត្តស្វាយរៀង ចាប់ពីថ្ងៃពុធ ១៥កើត ខែបឋមាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៨ រៀងរាល់ម៉ោងធ្វើការដល់វេលាម៉ោង០៩ និង០០នាទី ថ្ងៃព្រហស្បត្តិ៍ ១៤កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៨។

ឯកសារដេញថ្លៃ ដែលបានបំពេញរួចត្រូវប្រគល់ជូនអង្គភាពលទ្ធកម្មរដ្ឋបាលខេត្ត យ៉ាងយូរបំផុតម៉ោង ០៩ និង០០នាទី ថ្ងៃសុក្រ ១៥កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៨ ។

ការបើកឯកសារដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្មរដ្ឋបាលខេត្តស្វាយរៀង តាមអាសយដ្ឋានខាងលើ (សាលាខេត្តស្វាយរៀង) វេលាម៉ោង០៩ និង០០នាទី ថ្ងៃ សុក្រ ១៥កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស២៥៦២ ត្រូវនឹងថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១៨ ។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយអាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្មដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃអង្គារ ១៤កើត ខែបឋមាសាឍ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅស្វាយរៀង, ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ២០១៨

**ជ. អភិបាលខេត្ត និងជា**

ជ. ប្រធានគណៈកម្មាធិការលទ្ធកម្មរបស់រដ្ឋបាលខេត្ត

ប្រាក់_សុវណ្ណ

**ចម្លងជូន៖**

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
(អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
-អង្គភាពប្រឆាំងអំពើពុករលួយ
-ឯកសារកាលប្បវត្តិ